**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថាស្វាគមន៍

## របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ប្រធានវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី៣

**វិមានរដ្ឋាភិបាល, រាជធានីភ្នំពេញ,ថ្ងៃទី ០២-០៣ ខែមិថុនា ឆ្នាំ ២០១០**

- *សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត*
- *លោកជំទាវ និងឯកឧត្តម ជាសហសេវិកក្នុងរាជរដ្ឋាភិបាល*
- *លោកជំទាវ ឯកឧត្តម ប្រធានប្រតិភូនិងតំណាងដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍និងអង្គការសង្គមស៊ីវិល*
- *លោកជំទាវ ឯកឧត្តម លោក លោកស្រី*

1- អនុលោមតាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩កន្លងមក យើងទាំងអស់គ្នាបានមកជួបជុំគ្នានាថ្ងៃនេះ ដើម្បីប្រារព្ធពិធីបើក និងដំណើរការ**វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣** (CDCF) របស់យើង ។ អង្គវេទិកាទាំងមូលសូមសំដែងអំណរសាទរចំពោះព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ។ ដូចយើងទាំងអស់គ្នា បានរំពឹងទុក **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបើកវេទិកានាពេលនេះ ហើយអង្គវេទិកាសូមសំដែងកតញ្ញូតាធមិយ៉ាងជ្រាលជ្រៅបំផុត និងគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលបានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសបើក**វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣** និងថ្លែងសុន្ទរកថាគន្លឹះ ព្រមទាំងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ សម្រាប់ជាកុសលដល់ការងាររួមរបស់យើងទាំងអស់គ្នា ទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍ ។ ក្នុងនាមបណ្ឌិត **អ៊ូន ព័ន្ធមុនីរ័ត្ន** និងឯកឧត្តម **ឈៀង យ៉ាណារ៉ា** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ដែលយើងខ្ញុំទាំង៣រូបបានទទួលបុព្វសិទ្ធិកិត្តិយស និងភារកិច្ចពី **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ឱ្យរៀបចំ និងដឹកនាំវេទិកាលើកទី៣នេះ យើងខ្ញុំសូមការ

អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** ដើម្បីសំដែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្ដៅបំផុតចំពោះសមាជិក សមាជិកានៃរាជរដ្ឋាភិបាល និងគណៈប្រតិភូនៃដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលអញ្ជើញមកពីទីស្នាក់ការកណ្ដាល ទីស្នាក់ការប្រចាំតំបន់ និងដែលមាននិវេសនដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងចំពោះតំណាងអង្គការសង្គមស៊ីវិល និងដៃគូផ្នែកឯកជន ដែលបានអញ្ជើញចូលរួមក្នុងវេទិកាលើកទី៣ ។ យើងប្រារព្ធវេទិកានាពេលនេះ បន្ទាប់ពីរាជរដ្ឋាភិបាលបានដំណើរការប្រកបដោយជោគជ័យ នូវវេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន (G-PSF) លើកទី១៥ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ និងកិច្ចប្រជុំលើកទី១៦នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ កន្លងមក ។

2- **វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣**នេះ កំពុងប្រព្រឹត្តទៅក្នុងបរិស្ថានគ្របដណ្ដប់មួយដែលព្រះរាជាណាចក្រកម្ពុជាកំពុងបន្តក្រេបជញ្ជក់នូវសន្តិភាពពេញលេញ ឯកភាពទឹកដីទាំងស្រុង ដែលកើតចេញឡើងកាលពី១២ឆ្នាំមុននេះ ពី«**នយោបាយឈ្នះ- ឈ្នះ**» របស់ **សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ ក្នុងបរិស្ថានគ្របដណ្ដប់នេះ ក្រោមការដឹកនាំដ៏វៃឆ្លាសរបស់ **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** ព្រះរាជាណាចក្រកម្ពុជាកំពុងបន្តការអភិវឌ្ឍន៍របស់ខ្លួនយ៉ាងស្វាហាប់ ក្នុងបរិយាកាសអំណោយផលនៃស្ថេរភាពនយោបាយ សណ្ដាប់ធ្នាប់សង្គម និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងនៃការរក្សាបានទាំងស្រុងនូវអធិបតេយ្យភាព និងបូរណភាពទឹកដី ។ វេទិកាលើកនេះបានជ្រើសយក «***ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព- ដំណាក់កាលទី២*»** **តាមរយៈការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម** ធ្វើជាប្រធានបទស្នូលនៃវេទិកាលើកទី៣នេះ ហើយរបៀបវារៈនិមួយៗនៃអង្គវេទិកាត្រូវបានរៀបចំជុំវិញការពន្លឿនការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ ។ ក្នុងស្មារតីនេះ វេទិកាលើកនេះនឹងផ្ដល់កាលានុវត្តភាពសម្រាប់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ព្រមទាំងផ្នែកឯកជន ពិគ្រោះនិងពិភាក្សាអំពីវឌ្ឍនភាព បញ្ហាប្រឈម ព្រមទាំងរួមគ្នាកំណត់វិធានការចាំបាច់នានា សម្រាប់ពន្លឿនកិច្ចអភិវឌ្ឍន៍ប្រទេស ដើម្បីពង្រឹងភាពជាដៃគូ បង្កើនប្រសិទ្ធភាព និងគណនេយ្យភាពទ្វេទិសនៃធនធានសាធារណៈ សម្រាប់ឈានទៅសម្រេចឱ្យបាននូវបណ្ដាគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម ដែលជាឧបករណ៍របស់រាជរដ្ឋាភិបាលសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ។ លើសពីនេះ ក៏នឹងមានការប្រកាសតួលេខណែនាំពហុឆ្នាំស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ សម្រាប់គាំទ្រដល់ការអនុវត្តន៍គោលដៅទាំងនេះផងដែរ ។ តាងនាមរាជរដ្ឋាភិបាល ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំរបស់ដៃគូអភិវឌ្ឍន៍ ដែលបានផ្ដល់តួលេខណែនាំពហុឆ្នាំស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការ ទោបីជាប្រទេសខ្លះកំពុងប្រឈមនឹងការបាត់តុល្យភាពខាងថវិកាក៏ដោយ ដើម្បីវេទិកាមានជាបណ្ដើៗនូវទិន្នន័យសម្រាប់បូកសរុបនិងប្រកាសក្នុងរបៀបវារៈទី៥ នាថ្ងៃទី៣ ខែមិថុនាស្អែកនេះ ។ ក្នុងន័យនេះ យើងខ្ញុំសូមគាំទ្ររាល់វិធានការណ៍ប្រឆាំងអំពើអស្ថេរភាវូបនីយកម្មហិរញ្ញវត្ថុ ដែលប្រទេសអភិវឌ្ឍន៍ទាំងនោះបាន និងកំពុងប្រកាន់យក ដូចជាការចាប់បង្ខំឱ្យមានការប្រកាសព័ត៌មានជាសាធារណៈ (Mandatory Disclosure) ដូចដែលលោក **Michel Barnier** ស្នងការនៃសហគមន៍អឺរុបទទួលបន្ទុកខាងសេវាហិរញ្ញវត្ថុបានលើកឡើងនាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ ដើម្បីប្រឆាំងនឹងឈ្មួញកេងប្រវ័ញ្ចក្នុងទីផ្សារសញ្ញាប័ណ្ណ

(Bond markets) ដែលពួកគេបានប្រើប្រាស់អន្តរការីយកម្មនៃ Sovereign Credit Default Swaps Transactions ក្នុងការកេងប្រវ័ញ្ចនេះ ។

*- សម្តេច នាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត*

*- លោកជំទាវ ឯកឧត្តម លោក លោកស្រី*

3- អ្វីដែលជាវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងបណ្តាឆ្នាំកន្លងមក ពិសេសក្នុងចន្លោះពីវេទិកាលើកទី២ នាថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០០៨ មកវេទិកាលើកទី៣នេះ គឺការដាក់ចេញនិងការអនុវត្តន៍នូវគោលនយោបាយជាប្រព័ន្ធស៊ីសង្វាក់ និងប្រទាក់ក្រឡាគ្នា ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលាទៅនឹងឥទ្ធិពលនៃវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងនៃឌិនភាពសេដ្ឋកិច្ចសកលលោកមកលើសេដ្ឋកិច្ចកម្ពុជា ដើម្បីជួយស្រោចស្រង់វិស័យដែលទទួលរងផលប៉ះពាល់ផ្ទាល់ពីវិបត្តិ ព្រមទាំងពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់ប្រជាពលរដ្ឋកម្ពុជា ។ ក្រោមកិច្ចដឹកនាំដ៏ប៉ិនប្រសប់ ប្រាកដប្រជា និងរស់រវើករបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** សេដ្ឋកិច្ចកម្ពុជាបានឆ្លងផុតពីដំណាក់កាលដ៏ លំបាកលំបិនបំផុតនៃវិបត្តិសេដ្ឋកិច្ច ដោយរាជរដ្ឋាភិបាលរក្សាបានយ៉ាងគត់មត់នូវស្ថេរភាពសង្គម ស្ថេរភាព ម៉ាក្រូសេដ្ឋកិច្ច និងពង្រឹងបាននូវបរិស្ថានកាន់តែអនុគ្រោះសម្រាប់សេដ្ឋកិច្ច និងធុរកិច្ចទៀតផង ។ វេទិការាជរដ្ឋាភិបាល- ផ្នែកឯកជនដែលជាគំនិតផ្តួចផ្តើម និងត្រូវបានដឹកនាំផ្ទាល់ដោយ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានក្លាយជាយន្តការមួយចាស់ទុំ ហើយបានទទួលការវាយតម្លៃជាអន្តរជាតិ ជាយន្តការមានប្រសិទ្ធភាពខ្ពស់ចំណាត់ថ្នាក់លេខ១ ដែលធនាគារពិភពលោកបានវាយតម្លៃយន្តការរបៀបនេះនៅក្នុងប្រទេសចំនួន២៤ ។

4- ជាការពិត ការធ្លាក់ចុះនៃសេដ្ឋកិច្ចរបស់កម្ពុជាបានបង្ខំឱ្យរាជរដ្ឋាភិបាលកម្ពុជា ចាត់វិធានការណ៍វិត្ថារកម្មចំណាយ ពោលគឺការបង្កើនចំណាយដើម្បីដោះស្រាយវិបត្តិ និងទប់ទល់បច្ច័យអាក្រក់មកលើសេដ្ឋកិច្ចកម្ពុជា ទន្ទឹមនឹងតម្រូវការចំណាយក្នុងកិច្ចការការពារអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដីកម្ពុជា ។ ក្នុងឆ្នាំ២០១០ និងបណ្តាឆ្នាំទៅមុខ រាជរដ្ឋាភិបាលនៅតែរក្សាមហិច្ឆិតាខ្ពស់របស់ខ្លួនក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស ទោះបីកត្តាសត្យានុម័តពីក្រៅប្រទេសមិនអំណោយផលក៏ដោយ ។ នោះគឺ ដូចមានចែងក្នុង **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២** *«ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន នៅក្នុងបរិការណ៍អត្រាអតិផរណាទាប ក្នុងកម្រិតតួលេខមួយខ្ទង់»* និង *«ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រឱ្យបានលើស១% ក្នុងមួយឆ្នាំ និងការធានាកែលម្អសូចនាករសំខាន់ៗក្នុងវិស័យសង្គមកិច្ច ពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ»* ។ ឈរលើសមិទ្ធផលជាសារវន្តយ៉ាងច្រើនក្នុងរយៈកាលកន្លងមក រាជរដ្ឋាភិបាលបានប្តេជ្ញាបន្តជម្រុញការអនុវត្តន៍កម្មវិធីកំណែទម្រង់សំខាន់ៗ ដូចជាកំណែទម្រង់រដ្ឋបាលសាធារណៈ ក្នុងនោះមានវិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងជាពិសេសការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ទាំងអស់នេះសម្រេចទៅបានក្នុងសមោកាសនៃស្ថេរភាពនយោបាយ និងសុខសន្តិភាព ហើយសុទ្ធតែជាប្រការគន្លឹះបំផុត សម្រាប់កម្ពុជាបោះជំហានឆ្ពោះទៅមុខ ក្នុងការលើកកំពស់កម្រិតជីវភាពរបស់ប្រជាជន ការគោរពសិទ្ធិមនុស្ស ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការសម្រេចឱ្យ

បាននូវកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ដូចមានចែងក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២** ។

5- ទោះបីរាជរដ្ឋាភិបាលបានសម្រេចសមិទ្ធផលជាច្រើនក៏ដោយ ក៏រាជរដ្ឋាភិបាលនៅមានបញ្ហាប្រឈមដែលត្រូវជំនះដោះស្រាយក្នុងកិច្ចអភិវឌ្ឍន៍ ។ នោះគឺការបន្តកាត់បន្ថយភាពក្រីក្រឱ្យបានជាង ១% ក្នុងមួយឆ្នាំ ស្របតាមបាវចនា **«សមធម៌»** នៃយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២ ។ ការពន្លឿនកិច្ចអភិវឌ្ឍន៍វិស័យកសិកម្មពិសេស តាមរយៈការបង្កើនផលិតភាពក្នុងវិស័យកសិកម្ម កសិឧស្សាហកម្ម ការកែឆ្នៃកសិផលសម្រាប់នាំចេញ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ សម្រាប់ធានាសន្តិសុខស្បៀង និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន បានក្លាយជាអាទិភាពខ្ពស់ និងបន្ទាន់ បំផុតរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤នេះ ។ ហេតុនេះ ការជម្រុញការអភិវឌ្ឍន៍ **«មាសស»** តាមការចង្អុលរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និងការអនុវត្តន៍រួមគ្នាប្រកបដោយកិច្ចសម្របសម្រួលនូវយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍវិស័យកសិកម្ម និងទឹក ដែលប្រធានស្ថាប័នទាំង២ ទើបបានអនុមតិក្នុងពេលថ្មីៗកន្លងមកនេះ គឺជាបញ្ហាសំខាន់សម្រាប់ឈានទៅសម្រេចគោលដៅទាំងអស់នេះ ។ ក្នុងស្មារតីនេះ ទន្ទឹមនឹងការបន្តបង្កើនចំណាយមូលធនបន្ថែមក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលក៏ត្រូវការហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការ ទាំងក្នុងក្របខ័ណ្ឌឥតសំណង ទាំងក្នុងក្របខ័ណ្ឌនៃការខ្ចីមានលក្ខណៈសម្បទានច្រើនបន្ថែមទៀត ហើយក៏ត្រូវប្រើប្រាស់ហិរញ្ញប្បទានឱ្យបានចំទិសនិងមានប្រសិទ្ធភាពតាមអាទិភាពនានានៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម** ទើបកម្ពុជាសម្រេចបាននូវទិសដៅនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាបាន ។ បញ្ហាប្រឈមទាំងអស់ដូចរៀបរាប់ខាងលើបានក្លាយជាប្រធានបទសំខាន់សម្រាប់ពិភាក្សាក្នុងវេទិកាលើកនេះ ។

*- សម្តេច នាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត*
*- ឯកឧត្តម លោកជំទាវ លោក លោកស្រី*

6- ការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាប្រធានបទមួយ ដែលមជ្ឈដ្ឋានអន្តរជាតិក៏ដូចជាប្រទេសទទួលហិរញ្ញប្បទានបាន និងកំពុងយកចិត្តទុកដាក់ខ្ពស់ ពិសេស ការអនុវត្តន៍ឱ្យកាន់តែជាក់ស្តែងនូវ«**ផែនការសកម្មភាពទីក្រុងអាក្រា** (Accra Agenda for Action-AAA)» នាខែកញ្ញា ឆ្នាំ២០០៨ ទាំងនៅតាមប្រទេសផ្តល់ហិរញ្ញប្បទាន និងប្រទេសទទួលហិរញ្ញប្បទាន ។ វឌ្ឍនភាពគួរឱ្យលើកទឹកចិត្តកន្លងមករបស់កម្ពុជាត្រូវបានទទួលស្គាល់ទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតសកល ។ ជាក់ស្តែង យន្តការដែលរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តក្នុងរយៈពេលជាង៧ឆ្នាំកន្លងមក សម្រាប់សម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលមានតំណាងអង្គការសង្គមស៊ីវិលចូលរួមក្នុងក្រុមការងារបច្ចេកទេសចម្រុះចំនួន១៤ ក្នុងចំណោម ១៩ក្រុមការងារ ដើម្បីពង្រឹងភាពជាដៃគូនិងប្រសិទ្ធភាពក្នុងកិច្ចសហប្រតិបត្តិការ មានភាពកាន់តែចាស់ទុំ ហើយបានដំណើរការប្រកបដោយវិចារណញ្ញាណនិងប្រសិទ្ធភាព ។ យើងបានប្រើប្រាស់យ៉ាងពេញលេញ និងមានប្រសិទ្ធភាពខ្ពស់ នូវយន្តការនេះ សម្រាប់អនុវត្តគោលការណ៍នានានៃ «**ផែនការសកម្មភាពទីក្រុងអាក្រា**» ក៏ដូចជាសម្រាប់រៀបចំការងារនានាដែលពាក់ព័ន្ធនឹងវេទិកាលើកទី៣នេះ ។ លើសពីនេះ នាដើមឆ្នាំ២០១០ រាជរដ្ឋាភិបាលបានវាយតម្លៃ

លំអិតអំពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ។ របាយការណ៍វាយតម្លៃនេះបានប្រើប្រាស់ព័ត៌មានប្រាកដប្រជា និងសក្ខីកម្មជាច្រើន ដើម្បីលើកបង្ហាញពីវឌ្ឍនភាពដែលសម្រេចបាន បញ្ហាប្រឈម និងអនុសាសន៍ សម្រាប់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលបន្តអនុវត្តដើម្បីឈានទៅសម្រេចគោលដៅស្តីពីប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិនៃហិរញ្ញប្បទាន ។ ដៃគូអភិវឌ្ឍន៍ជាច្រើនបានវាយតម្លៃខ្ពស់អំពីគុណភាពនៃរបាយការណ៍ ហើយក៏បានឯកភាពជាមួយនឹងរាជរដ្ឋាភិបាលថា បញ្ហាបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាបញ្ហាសំខាន់និងបន្ទាន់ ហើយបានឯកភាពជាមួយនឹងរាជរដ្ឋាភិបាល បញ្ចូលបញ្ហានេះជារបៀបវារៈមួយដ៏សំខាន់សម្រាប់ពិភាក្សាក្នុងវេទិកាលើកនេះ ។ ក្នុងឱកាសដ៏ប្រពៃនេះ ក្នុងឋានៈខ្ញុំជាប្រធានវេទិកាលើកនេះ ខ្ញុំសូមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេច នាយករដ្ឋមន្ត្រី** និងពីអង្គវេទិកា ដើម្បីវាយតម្លៃខ្ពស់ចំពោះតួនាទី និងការខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ឈៀង យ៉ាណារ៉ា** ដែលបានជម្រុញការអនុវត្តន៍របៀបវារៈស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្នុងឋានៈជាអគ្គលេខាធិការនៃវេទិកាលើកនេះ ក្រោមកិច្ចដឹកនាំផ្ទាល់របស់ខ្ញុំជាប្រធានវេទិកា និងឯកឧត្តម **អូន ព័ន្ធមុន្នីរ័ត្ន** ជាប្រធានបំរុងនៃវេទិកា និងដោយមានកិច្ចសហការយ៉ាងស្អិតរម្មួតជាមួយសហសេវិកក្នុងរាជរដ្ឋាភិបាល ឯកឧត្តម **ឈៀង យ៉ាណារ៉ា** បានសម្របសម្រួល ទាំងខាងបច្ចេកទេស និងទាំងខាងរដ្ឋបាលសម្រាប់វេទិកាលើកនេះ និងកិច្ចប្រជុំនានាចន្លោះ ពីវេទិកាមួយទៅវេទិកាមួយប្រកបដោយប្រសិទ្ធភាព ស្របតាមកាតព្វកិច្ចរបស់ស្ថាប័ននេះ ដែលជាចំណុចប្រមូលផ្តុំនៃការសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ។

*- សម្តេច នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី*

7- វឌ្ឍនភាពដែលកម្ពុជាសម្រេចកន្លងមក គឺបានមកពីការប្តេជ្ញាចិត្តខ្ពស់ និងសកម្មភាពជាក់ស្តែង និងចំគោលដៅ ក្រោមកិច្ចដឹកនាំដ៏មោះមុត និងប៉ិនប្រសប់របស់ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** រួមផ្សំជាមួយនឹងវិភាគទានដ៏ធំធេង និងធាតុចូលដ៏ថ្លៃថ្លាពីសំណាក់ដៃគូអភិវឌ្ឍន៍ ។ វេទិកាយើងនឹងត្រងត្រាប់ស្តាប់តាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដើម្បីបានជាទុន ជាកុសលសម្រាប់ពិភាក្សាក្នុងវេទិកានេះ ។ ក្នុងន័យនេះ បន្ទាប់ពីអន្តរាគមន៍របស់តំណាងដៃគូអភិវឌ្ឍន៍ដែលត្រូវបានជ្រើសតាំងសម្រាប់វេទិកាលើកនេះ វេទិកាយើងនឹងមានកិត្តិយសសូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឡើងថ្លែងសុន្ទរកថា និងផ្តល់សារគន្លឹះក្នុងឱកាសបើកវេទិកាលើកទី៣នេះ ។ ខ្ញុំសូមអនុញ្ញាតអញ្ជើញលោកស្រី **Annette Dixon** តំណាងដៃគូអភិវឌ្ឍន៍ឡើងកាន់វេទិកា ។

**សូមអរគុណ !**